## ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

# សេចក្តីប្រកាសព័ត៌មាន

## កម្មវិធីផ្លាស់ប្តូរយុវជន JENESYS 2016

## ( ក្រុមទី១ )

ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៦

ឆ្លើយតបតាមការអញ្ជើញរបស់ក្រសួងការបរទេសជប៉ុននៃកម្មវិធីផ្លាស់ប្តូរយុវជនសិស្សនិស្សិតជប៉ុន និងអាស៊ីបូព៌ា ២០១៦ (JENESYS 2016) សិស្សវិទ្យាល័យកម្ពុជា២៣រូបនឹងធ្វើទស្សនកិច្ចទៅកាន់ប្រទេសជប៉ុនពីថ្ងៃទី១៨ ដល់ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៦។

កម្មវិធី JENESYS 2016 មានគោលបំណងជម្រុញការយល់ដឹង និងទំនុកចិត្តគ្នាទៅវិញទៅមកក្នុងចំណោមប្រជាជនជប៉ុន និង បណ្តាប្រទេសដែលចូលរួម និងដើម្បីកសាងមូលដ្ឋានគ្រឹះនៃកិច្ចសហប្រតិបត្តិការ និងចំណងមិត្តភាពនាពេលអនាគត។

ក្រុមសិស្សនឹងធ្វើទស្សនកិច្ចទៅកាន់ទីក្រុងតូក្យូ និង កោះហុកកៃដូ ដើម្បីចូលរួមកម្មវិធីផ្លាស់ប្តូរ ក្រោមប្រធានបទ“ វិទ្យាសាស្រ្ត និង បច្ចេកវិទ្យា”។ ពួកគេក៏នឹងមានឱកាសធ្វើទស្សនកិច្ចនៅសារមន្ទីរជាតិMiraikan(សារមន្ទីរជាតិវិទ្យាសាស្រ្ត និង ការច្នៃប្រឌិតថ្មី) មជ្ឍមណ្ឌលវិទ្យាសាស្រ្តSapporo និងមជ្ឍមណ្ឌលអប់រំវិទ្យាសាស្រ្ត ហើយរួមជាមួយសាកលវិទ្យាល័យហុកកៃដូ ដើម្បីយល់ដឹងពីបច្ចេកវិទ្យាទំនើបជប៉ុន ក៏ដូចជាការចូលរួមកម្មវិធីផ្លាស់ប្តូរបទពិសោធន៍សាលារៀនជាមួយ

សិស្សនៃវិទ្យាល័យបច្ចេកវិទ្យានិងវប្បធម៌Sapporoហុកកៃដូ។ ចំពោះកម្មវិធីលម្អិតមានភ្ជាប់មកជាមួយ។

យើងខ្ញុំសង្ឃឹមថាអ្នកចូលរួមនឹងយល់ដឹងអំពីប្រទេសជប៉ុន ហើយបន្ទាប់ពីត្រលប់មកវិញ ពួកគេនឹងចែករំលែកបទពិសោធរបស់ពួកគេទៅកាន់ប្រជាជនកម្ពុជាកាន់តែទូលំទូលាយ។

---

*Embassy of Japan in the Kingdom of Cambodia*

*Tel: 023 217 161*

*Email: info.jpn@pp.mofa.go.jp*

*Official Website: www.kh.emb-japan.go.jp*